ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធមណ្ឌលវិបស្សនាធុរៈ
នៃព្រះរាជាណាចក្រកម្ពុជា

# ធម្មគារវ ( ការគោរពធម៌ )



ព្រះឧបាលិវង្ស ម៉ឺន សែស ចៅអធិការ វត្តមហាមន្ត្រី

ប្រែនឹងរៀបរៀង

សៀវភៅធម្មគារវនេះ និយាយអំពីការគោរពធម៌ដោយសង្ខេប ខ្ញុំបានស្រាវជ្រាវរៀបរៀងឡើង ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនទាំងឡាយ ដែលត្រូវការសិក្សារៀនសូត្រធម្មវិន័យ ពុទ្ធសាសនា ការដែលរៀនហើយត្រូវតែប្រតិបត្តិតាម ត្រូវតែគោរពទើបមានផលានិសង្សច្រើន ព្រោះហេតុនោះ សប្បុរសទាំងឡាយគួរសិក្សារៀនសូត្រឲ្យចេះចាំច្បាស់លាស់ ហើយគោរពឲ្យមែនទែន យកដំរាប់ដំរាតាមព្រះពុទ្ធជាម្ចាស់ នឹងព្រះបរមចក្រពត្រាធិរាជរាល់ៗ ព្រះអង្គដែលកន្លងទៅហើយ នឹងបានសេចក្តីសុខ – ចំរើនក្នុងលោកនេះនឹងលោកខាងមុខ នឹងបានសម្រេចព្រះនិព្វានជាអវសាន ។

## គារវសូត្រ

ខ្ញុំបានស្តាប់មកយ៉ាងនេះ សម័យមួយព្រះដ៏មានព្រះភាគទ្រង់បានត្រាស់ដឹងជាដំបូង ទ្រង់គង់ក្រោមដើមអជបាលនិគ្រោធទៀបឆ្នេរស្ទឹង នេរញ្ជរា ក្នុងឧរុវេលាប្រទេស ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពួនសម្ងំនៅក្នុងទីស្ងាត់ ទ្រង់ព្រះដំរិះថា សត្វដែលមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង រមែងនៅជាទុក្ខ ចុះតថាគតគួរសក្ការៈគោរពអាស្រ័យនឹងសមណ ឬព្រាហ្មណ៍ណាហ្ន៎ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ព្រះដំរិះតទៅទៀតថា គួរតែតថាគតសក្ការគោរពអាស្រ័យនូវសមណ ឬព្រាហ្មណ៍ដទៃ ដើម្បីបំពេញនូវសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធ ដែលមិនទាន់ពេញលេញ តែថាក្នុងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស តថាគតមិនឃើញមានសមណ ឬព្រាហ្មណ៍ដទៃដែលមានសីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធ ពេញលេញជាងតថាគតឡើយ បើដូច្នោះធម៌ឯណាដែលតថាគតបានត្រាស់ដឹងហើយ គួរតថាគតសក្ការគោរពអាស្រ័យនូវធម៌នោះតែប៉ុណ្ណោះចុះ ។

គ្រានោះ សហម្បតីព្រហ្មបានជ្រាបព្រះដំរិះ របស់ព្រះដ៏មានព្រះភាគដូច្នោះហើយ ក៏ចុះចាកព្រហ្មលោកមកប្រាកដក្នុងទីចំពោះព្រះភក្ត្រ ព្រះដ៏មានព្រះភាគដោយឆាប់រហ័ស ប្រហែលគ្នានឹងបុរសមានកំលាំង លាចេញនូវដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញ ។ លំដាប់នោះ សហម្បតីព្រហ្មពានាសំពត់បង់កឆៀងស្មាម្ខាង ហើយប្រណម្យអញ្ជលីឆ្ពោះទៅរកព្រះដ៏មានព្រះភាគ ហើយក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ព្រះដំរិះនោះត្រូវហើយៗព្រោះថា ព្រះអរហន្តសម្មាសម្ពុទ្ធក្នុងអតីតកាលលោកគោរពតែត្រឹមធម៌ប៉ុណ្ណោះ ព្រះអរហន្តសម្មាសម្ពុទ្ធក្នុងអនាគតកាល ក៏គោរពតែត្រឹមធម៌ប៉ុណ្ណោះដែរ ចំណែកព្រះអង្គជាអរហន្តសម្មាសម្ពុទ្ធក្នុងបច្ចុប្បន្ននេះ ក៏សូមគោរពតែត្រឹមធម៌ប៉ុណ្ណឹងចុះ ។ ទើបសហម្បតីព្រហ្មពោលពាក្យនេះតទៅទៀតថា :

យេ ច អតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា
យោ ចេតរហិ សម្ពុទ្ធោ ពហុន្នំ សោកនាសនោ
សព្វេ សទ្ធម្មគរុនោ វិហរឹសុ វិហរន្តិ ច
អថាបិ វិហរិស្សន្តិ ឯសា ពុទ្ធាន ធម្មតា

តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា
សទ្ធម្មោ គរុកាតព្វោ សរំ ពុទ្ធាន សាសនន្តិ ។

ព្រះសម្ពុទ្ធក្នុងអតីតកាលក្តី ព្រះសម្ពុទ្ធក្នុងអនាគតកាលក្តី ព្រះសម្ពុទ្ធក្នុងបច្ចុប្បន្ននេះក្តី រមែងញុំាងសេចក្តីសោករបស់ជនច្រើនឲ្យវិនាស លោកមានសេចក្តីគោរពព្រះសទ្ធម្មទាំងអស់នេះជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ព្រោះហេតុនោះ អ្នកដែលស្រឡាញ់ខ្លួនប្រាថ្នានឹងធ្វើខ្លួនឲ្យថ្លៃថ្លា គួររលឹកសាសនារបស់ព្រះពុទ្ធ គួរគោរពព្រះសទ្ធម្មឲ្យមាំមួន ។

(**ចប់គារវសូត្រ**)

ក៏ឯព្រះសទ្ធម្មនោះ មាន៣យ៉ាង គឺបរិយត្តិសទ្ធម្ម បានដល់ពុទ្ធវចនៈទាំងអស់ សង្គ្រោះដោយបិដកទាំង៣ គឺវិនយបិដក សុត្តន្តបិដក អភិធម្មបិដក ជាធម៌ចង្អុលប្រាប់ផ្លូវប្រតិបត្តិ គឺ សីលសមាធិ វិបស្សនា មគ្គនឹងផល និព្វាន ១ ។ បដិបត្តិសទ្ធម្ម បានដល់ធុតង្គគុណ ១៣ ខន្ធកវត្ត ១៤ មហាវត្ត ៨២ នឹងសីល សមាធិ វិបស្សនា ១ ។ អធិគមសទ្ធម្ម បានដល់អរិយមគ្គ ៤ សាមញ្ញផល ៤នឹងព្រះនិព្វាន ១ ។

សេចក្តីនេះ ឃើញថាព្រះបរមគ្រូទ្រង់គោរពធម៌ដូចបានពោលមកហើយ ចំណែកសត្វដទៃក៏គួរគោរពធម៌ដូច្នោះដែរ ព្រោះពួកសត្វដែលគ្មានការគោរព រមែងគ្មានសេចក្តីសុខ ចំរើនឡើយ ហេតុដូច្នោះ ពួកសប្បុរសទាំងបព្វជិត ទាំងគ្រហស្ថគួរគោរពព្រះសទ្ធម្មទាំង៣ យ៉ាងនោះដោយអើពើ ។ ឯពាក្យថា «គោរពព្រះសទ្ធម្»នោះ គឺសិក្សារៀនសូត្រ ស្តាប់ព្រះវិនយបិដកឲ្យចេះចាំច្បាស់លាស់ ហើយកាន់តាម ប្រតិបត្តិតាមសិក្ខាបទ ដែលព្រះអង្គបញ្ញត្តអនុញ្ញាតទុកមកយ៉ាងណា ហៅថាគោរពព្រះសទ្ធម្ម គឺ វិនយបិដក ។

កុលបុត្រសិក្សារៀនសូត្រស្តាប់ព្រះសុត្តន្តបិដក ជាធម៌សំដែងអំពីផ្លូវប្រតិបត្តិ កុសល អកុសល បុណ្យ បាប គុណ ទោស បានចេះចាំ ច្បាស់លាស់ហើយកាន់តាម ប្រតិបត្តិតាមព្រះសូត្រនោះៗ ហៅថាគោរពព្រះសទ្ធម្ម គឺ ព្រះសុត្តន្តបិដក ។

កុលបុត្រសិក្សារៀនសូត្រស្តាប់ព្រះអភិធម្មបិដក ជាធម៌សំដែងអំពីចិត្ត ចេតសិក រូប និព្វាន ជាដើម បានចេះចាំច្បាស់លាស់ហើយ កាន់តាមប្រតិបត្តិតាម ហៅថាគោរពព្រះសទ្ធម្ម គឺ ព្រះអភិធម្មបិដក ។ ទាំង៣យ៉ាងនេះ ហៅថាគោរពបរិយត្តិសទ្ធម្ម ។

ពួកកុលបុត្រប្រព្រឹត្តត្រឹមត្រូវក្នុង ធុតង្គគុណទាំង១៣ ជាធម៌ញុំាងសីលឲ្យផូរផង់ឲ្យក្រអូបក្រអែបឈ្ងុយឈ្ងប់ឡើង ប្រព្រឹត្តត្រឹមត្រូវក្នុងខន្ធកវត្ត ១៤(*១) នឹងមហាវត្ត៨២(*២)ទាំងប្រព្រឹត្តសីលឲ្យបរិសុទ្ធល្អលុះសីលបរិសុទ្ធហើយ ក៏សិក្សារៀនសមថកម្មដ្ឋាន ខំចំរើនពិចារណាត្រាតែបានសម្រេចភូមិសមាធិ ឬសមាបត្តិទាំង៨គឺ រូបសមាបត្តិ ៤ អរូបសមាបត្តិ ៤ បានសម្រេចសមាធិហើយ ក៏សិក្សារៀនសូត្រក្នុងវិបស្សនាកម្មដ្ឋាន ខំចំរើនពិចារណាត្រាតែបានសម្រេចរហូតដល់គោត្រភូញាណ ដូច្នេះហៅថាគោរពព្រះសទ្ធម្ម គឺបដិបត្តិសទ្ធម្ម ។

កុលបុត្របំពេញសេចក្តីប្រតិបត្តិ គឺសីល សមាធិ បញ្ញា បានសម្រេចមគ្គផល និព្វាន ហៅថាគោរពព្រះសទ្ធម្ម គឺអធិគមសទ្ធម្ម ។ មួយទៀត បរិសទ្យទាំង៤ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា បានគោរពធម៌

ប្រតិបត្តិធម៌ របស់ព្រះសម្មាសម្ពុទ្ធហើយ ក៏ឈ្មោះថាគោរពប្រតិបត្តិបូជាដល់ព្រះពុទ្ធជាម្ចាស់ផង នឹងបានផលានិសង្សយ៉ាងវិសេស ដូចព្រះបាលីថា:

យោ ខោ អានន្ទ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា
ឧបាសិកា វា ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ
អនុធម្មចារី សោ តថាគតំ សក្ការេតិ គរុករោតិ
មានេតិ បូជេតិ បរមាយ បូជាយ ។

ម្នាលអានន្ទ បុគ្គលឯណាមួយ ជាភិក្ខុក្តី ភិក្ខុនីក្តី ជាឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយផ្ចិតផ្ចង់ ជាអ្នកប្រព្រឹត្តតាមគន្លងធម៌ បុគ្គលនោះបានឈ្មោះថាសក្ការគោរពរាប់អានបូជាព្រះតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ។

ពាក្យថា «ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌»នោះគឺបុព្វភាគប្រតិបត្តិដ៏សមគួរដល់លោកុត្តរធម៌ទាំង ៩ ។ ឯបុព្វភាគប្រតិបត្តិនោះ គឺសេចក្តីប្រតិបត្តិជាចំណែកខាងដើម បានដល់សីលនឹងអាចារប្បញ្ញត្តិ នឹងធុតង្គសមាទាន ។ ពាក្យថា «ប្រតិបត្តិដោយផ្ចិតផ្ចង់»បានដល់ការប្រតិបត្តិ សមាធិ វិបស្សនា រហូតដល់គោត្រភូញាណ ។ សេចក្តីគោរពធម៌របស់បរិសទ្យទាំង៤ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរយ៉ាងនេះឯង ។ មួយទៀត សូម្បីព្រះបរមចក្រពត្រាធិរាជក៏ទ្រង់មានសេចក្តីគោរពព្រះធម៌ដែរ ដូចមានរឿងក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាតថា :

សម័យមួយ មានភិក្ខុមួយអង្គចូលទៅក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សភាវៈដូចម្តេចជាស្តេច គឺជាធំលើព្រះរាជាចក្រពត្តិដែលទ្រង់ធម៌? ព្រះអង្គមានព្រះបន្ទូលថា :

ឥធ ភិក្ខុ រាជា ចក្កវត្តី ធម្មិកោ ធម្មរាជា ធម្មញ្ញេវ
និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ
អបចាយន្តោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ
ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហាតិ អន្តោជនស្មឹ ។

ម្នាលភិក្ខុ ព្រះរាជាចក្រពត្តិក្នុងលោកនេះ ជាធម្មរាជប្រកបដោយធម៌ ទ្រង់អាស្រ័យនូវធម៌ ទ្រង់សក្ការធម៌ គោរពធម៌ កោតក្រែងធម៌ មានធម៌ជាទង់ជ័យ មានធម៌ជាទង់សំគាល់យស មានធម៌ជាធំ ទ្រង់ចាត់ចែងនូវការរក្សា ការពារគ្រប់គ្រងប្រកបដោយធម៌ដល់ពួកជនដែលនៅក្រោមបង្គាប់ ។ ពាក្យថា«ធម៌» ក្នុងទីនេះ សំដៅយកកុសលកម្មបថ ១០ គឺ កាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣ បានសេចក្តីថា ព្រះបាទបរមចក្កពត្តិរាជ ទ្រង់គោរពធម៌ គឺកុសលកម្មបថ ១០ ហេតុនោះមនុស្សទាំងឡាយគួរគោរពកុសលកម្មបថនោះ តាមគន្លងព្រះបាទចក្កពត្តិរាជ ជាធម៌ធ្វើខ្លួនឲ្យថ្លៃថ្លារៀងរាល់ជាតិ ។

មួយវិញទៀត កុសលកម្មបថនេះបើបុគ្គលបានគោរព គឺថាបានប្រតិបត្តិដោយប្រពៃហើយ ក៏អាចឲ្យសំរេចសម្បត្តិទាំង៣ប្រការ គឺបានជាអ្នកថ្កើងខ្ពស់ក្នុងមនុស្សលោក ១ បានទៅកើតជាទេវតាដោយសម

គួរតាមប្រាថ្នា តាំងអំពីស្ថានចាតុម្មហារាជិកា រហូតដល់អកនិដ្ឋព្រហ្ម ១ បានសំរេចអរហត្តផល ជាទីបំផុត ជាតិ ជរា ព្យាធិ មរណៈ ១ ។

សមតាមបាលីពុទ្ធភាសិត សាលេយ្យកសូត្រ គម្ពីរមជ្ឈិមនិកាយមូលបណ្ណាសក សេចក្តីក្នុងសូត្រនោះថា បុគ្គលពួក១ក្នុងលោកនេះលះបង់បាណាតិបាត វៀរចាកបាណាតិបាត លែងកាន់ដំបងគ្រឿងវាយសំពងសត្វ លែងកាន់សស្ត្រាវុធគ្រឿងប្រហារជីវិតសត្វ(សត្វក្នុងទីនេះសំដៅយកទាំងមនុស្ស ទាំងសត្វតិរច្ឆាន) មានសេចក្តីខ្មាសបាប ខ្ពើមបាប ប្រកបដោយសេចក្តីអាណិតអាសូរសព្វសត្វ ដោះសត្វឲ្យរួចអំពីទុក្ខលំបាក ត្រូវការទំនុកបំរុងឲ្យបានសេចក្តីសុខ ចំរើន ។ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន មិនបានប្លន់កំហែងដណ្តើមយកទ្រព្យគេ មិនលួចលាក់ឆក់បំបាត់ប្រវ័ញ្ចន៍បោកប្រាស់ គៃបន្លំយកទ្រព្យអ្នកដទៃ ។ លះបង់កាមេ សុមិច្ឆាចារ វៀរចាកកាមេ សុមិច្ឆាចារ មិនបានសេពសម្ភពគប់រក ឬប្រព្រឹត្តអសទ្ធម្មចំពោះស្ត្រីដែលមានមាតាថែរក្សា មានបិតាបងប្អូនប្រុស បងប្អូនស្រី ពួកញាតិថែរក្សា នឹងស្ត្រីដែលមានប្តីគ្រប់គ្រង នឹងស្ត្រីដែលមានព្រះរាជាត្រូវការឲ្យថែរក្សាដាក់អាជ្ញាព្រះរាជទណ្ឌ មិនឲ្យបុរសណាមួយទៅប្រព្រឹត្តល្មើសតាមអំពើចិត្ត ។ ដូច្នេះហៅថាកាយកម្ម៣ ។

បុគ្គលពួក១ក្នុងលោកនេះ លះបង់មុសាវាទ វៀរចាកមុសាវាទ ទោះបីទៅក្នុងទីប្រជុំក្តី ទៅក្នុងកណ្តាលបរិសទ្យក្តី ទៅក្នុងកណ្តាលពពួកញាតិក្តី ទៅក្នុងកណ្តាលពពួកសេនាក្តី ទៅក្នុងកណ្តាលរាជត្រកូល ដោយគេនាំទៅធ្វើជាសាក្សី ដើម្បីសួរបញ្ជាក់រឿងក្តីណាមួយក្តី ក៏និយាយតាមពិត តាមមែន តាមដឹង តាមឃើញ មិននិយាយពាក្យកុហកបញ្ឆោតបង្កាច់ផ្តាច់ប្រយោជន៍អ្នកដទៃ ។ លះបង់បិសុណាវាចា វៀរចាកបិសុណាវាចា ជាពាក្យញុះញង់ ឬ ស៊កសៀត មិនបានឮពាក្យសំដីអំពីអ្នកឯណេះ ហើយនាំយកទៅប្រាប់អ្នកឯណោះ ដើម្បីបំបែកអ្នកឯណេះ ឬថាមិនបានឮពាក្យសំដីអំពីអ្នកឯណោះហើយ នាំយកមកប្រាប់អ្នកឯណេះ ដើម្បីបំបែកអ្នកឯណោះវិញ កាលបើមានគេទាស់ទែងគ្នា បាក់បែកគ្នា ក៏យកចិត្តទុកដាក់និយាយផ្សះផ្សាឲ្យជានឹងគ្នា កាលបើគេជានឹងគ្នាស្រាប់ហើយ ក៏និយាយថែមកម្លាំងឲ្យរឹងរឹតតែជានឹងគ្នាឡើងទៀត ជាអ្នកត្រេកអរស្រឡាញ់ចូលចិត្តនឹងការព្រមព្រៀងគ្នា តែងពោលនូវវាចាធ្វើឲ្យគេព្រមព្រៀងគ្នា ។ លះបង់ផរុសវាចា វៀរចាកផរុសវាចា ជាពាក្យអាក្រក់ទ្រគោះ គម្រោះគម្រាមជេរឌីដងចាក់ដោតបញ្ឈឺចិត្ត ពោលតែពាក្យល្អឥតទោស នាំមកនូវសេចក្តីសុខដល់ត្រចៀក ជាពាក្យទន់ផ្អែម ពីរោះគួរស្រឡាញ់ គួរចូលចិត្ត ។ លះបង់សម្ផប្បលាប វៀរចាកសម្ផប្បលាប ជាពាក្យរោយរាយឥតប្រយោជន៍ ជាពាក្យត្លុកកំប្លែងលេងសើចឥតអំពើ ពោលតែពាក្យដែលមានប្រយោជន៍ដល់ខ្លួននឹងអ្នកដទៃ ពោលក្នុងកាលដែលគួរ ពោលពាក្យពិត ពាក្យដែលត្រូវតាមអត្ថ តាមធម៌តាមវិន័យ ។ ដូច្នេះហៅថាវចីកម្ម៤ ។

បុគ្គលពួក១ក្នុងលោកនេះ មិនចង់បានទ្រព្យអ្នកដទៃមកជាទ្រព្យរបស់ខ្លួន មិនរលេមរលមឆ្មៀងឈ្មងគយគន់រំពៃ ប៉ងនឹងបង្អានទ្រព្យអ្នកដទៃមកដើម្បីខ្លួន ។ មិនមានចិត្តប៉ុនប៉ងនឹងធ្វើប្រយោជន៍ នឹងសេចក្តីសុខរបស់អ្នកដទៃឲ្យវិនាស ។ មានបញ្ញាយល់ត្រូវតាមសភាវៈធម៌ មិនបានយល់ខុសចាកសភាវៈធម៌ ។ ដូច្នេះហៅថាមនោកម្ម ៣ ។ កាយកម្ម៣ វចីកម្ម ៤ មនោកម្ម ៣ ដូចបានពោលមកនេះហៅថា

កុសលកម្មបថ ១០ ។ ឯកុសលកម្មបថនេះ បើបុគ្គលឯណាបានគោរពគឺថា បានប្រព្រឹត្តត្រឹមត្រូវល្អហើយ ទោះបីបុគ្គលនោះមានចិត្តប្រាថ្នាចង់ទៅកើតក្នុងត្រកូលខត្តិយមហាសាលក្តី ព្រាហ្មណ៍មហាសាលក្តី គហបតិមហាសាលក្តី ក៏បានសំរេចដូចប្រាថ្នាមិនខានឡើយ ។ ពាក្យថា «ខត្តិយមហាសាល» គឺត្រកូលក្សត្រដែលមានទ្រព្យឧត្តុង្គឧត្តមច្រើន ព្រាហ្មណមហាសាល នឹងគហបតិមហាសាលក៏ដូចគ្នា ។ មួយទៀត បើប្រាថ្នាចង់ទៅកើតជាទេវតាក្នុងស្ថានចាតុម្មហារាជិកា ... តាវត្តិង្ស.... យាមា... តុសិត.....និម្មានរតី.... បរនិម្មិតវសវត្តី ក៏បានសំរេចដូចប្រាថ្នាមិនខាន ។ មួយទៀត បើមានប្រាថ្នានឹងទៅកើតក្នុងព្រហ្មលោក តាំងអំពីព្រហ្មបារិសជ្ជារហូតដល់អកនិដ្ឋព្រហ្ម ក៏បានសំរេចដូចប្រាថ្នា ។ មួយទៀត បើប្រាថ្នាចង់ឲ្យបានអរហត្តផលដ៏ខ្ពង់ខ្ពស់ជាងធម៌ទាំងពួង ក៏បានសំរេចដូចប្រាថ្នា ដោយហេតុដែលបានប្រព្រឹត្តកុសលកម្មបថនោះជាប្រធាន ។ ការប្រព្រឹត្តកុសលកម្មបថអាចឲ្យបានសំរេចសម្បត្តិ ៣ ប្រការដូច្នេះឯង ។

ចប់តែប៉ុណ្ណេះ ។

---

(*១) ខន្ធកវត្ត ១៤ មានអាគន្តុកវត្ត គឺវត្តរបស់អាគន្តុកភិក្ខុជាដើម មកក្នុងវត្តក្ខន្ធកគម្ពីរចុល្លវគ្គ ។

(*២) មហាវគ្គ ៨២ ដែលព្រះអង្គបញ្ញត្តទុកមានពាក្យថា ន ឧបសម្បាទេតព្វំ ភិក្ខុមិនត្រូវឲ្យឧបសម្បទាដល់កុលបុត្រជាដើម មកក្នុងបារិវាសិកក្ខន្ធកខ្លះ កម្មក្ខន្ធកត្រង់ ឧក្ខេបនិយកម្មខ្លះ គម្ពីរចុល្លវគ្គ ។

Source: https://khmerbuddhism.wordpress.com

***Website: BVDCC.org***

***E-mail: Chhenchhoun@gmail.com***

***YouTube: Vipassana Dhurak Buddhist Centre***

***YouTube: ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា***